# ឯកសារទស្សនទាន

## វេទិកាលើកទី ៨ របស់អង្គការមិនមែនរដ្ឋាភិបាលដែលទទួលបានវិញ្ញាបនបត្រ

## ស្តីអំពី

## "ការលើកកម្ពស់ប្រសិទ្ធភាពការអភិវឌ្ឍ របស់អង្គការសង្គមស៊ីវិល នៅក្នុងបរិបទ អភិបាលកិច្ចល្អ នៃអង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា"

## ថ្ងៃទី១០ ខែមិថុនា ឆ្នាំ ២០១៤ នៅអាគារ *KSSA* រាជធានីភ្នំពេញ

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ( CCC ) គឺបានបង្កើតឡើង និងមានចូលរួមយ៉ាងសកម្ម ពីសំណាក់អង្គការជាង ១៦០ នៃអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ (INGO) និងអង្គការក្រៅរដ្ឋាភិបាលជាតិ នៅក្នុងប្រទេសកម្ពុជា (LNGO) ។ ចាប់តាំងពីឆ្នាំ ២០១១ CCC បានពិនិត្យឡើងវិញទិសដៅជាយុទ្ធសាស្រ្តរបស់ខ្លួន និងបានអនុម័ត ទស្សនៈវិស័យ និងបេសកកម្មថ្មី ដែលហៅថាចក្ខុវិស័យឆ្នាំ ២០១៥ ដោយរួមបញ្ចូលគ្នានៃកម្មវិធីមួយៗ និង កម្មវិធីរយៈពេលវែង ៥ ឆ្នាំ ទៅជាកម្មវិធីតែមួយ ដែលមានឈ្មោះ កម្មវិធីអភិបាលកិច្ច ( GHP ) ឆ្នាំ ២០១១ ដល់ ២០១៥ ហើយក៏ត្រូវបានអនុម័តផងដែរដោយមានទស្សនៈវិស័យទូលំទូលាយ ដែលសំដៅទៅលើ សង្គមស៊ីវិល មួយដែលមានកិច្ចសហការដ៏រឹងមាំនិងមានសមត្ថភាពឆ្លើយតបទៅនឹងបញ្ហានៃការអភិវឌ្ឍនៅប្រទេសកម្ពុជា។

លើសពីនេះទៀត ដើម្បីឲ្យមានភាពពាក់ព័ន្ធមានប្រសិទ្ធភាព និងឆ្លើយតបទៅនឹងគំរូអភិឌ្ឍន៍ថ្មី កើតឡើងជាលក្ខណៈជាតិ និងអន្តរជាតិ។ CCC បានធ្វើឱ្យកិច្ចខិតខំប្រឹងប្រែងដ៏អស្ចារ្យមួយផ្សេងទៀត ក្នុងការកែប្រែកម្មវិធី GHP ឆ្នាំ ២០១១ ដល់ ២០១៥ របស់ខ្លួន ហើយពេលបច្ចុប្បន្នកំពុងលេចចេញមកជាមួយនូវទស្សនៈនិង GHP កាន់តែជាក់លាក់សម្រាប់ ឆ្នាំ ២០១៤ ដល់ ២០១៨។

ចាប់តាំងពីឆ្នាំ ២០០៤ CCC បានផ្តួចផ្តើមកម្មវិធីអភិបាលកិច្ច និង ការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ (NGO GPP) សម្រាប់អង្គការមិនមែនរដ្ឋាភិបាល ដើម្បីធានាថាអង្គការក្រៅរដ្ឋាភិបាលអនុវត្តតាម បទដ្ឋានអប្បបរមានៃការអនុវត្តល្អនិង វិជ្ជាជីវៈសម្រាប់អង្គការមិនមែនរដ្ឋាភិបាល ដើម្បីឲ្យកាន់តែមានគណនេយ្យភាព និងមានប្រសិទ្ធភាព ក្នុងការលើកកម្ពស់អភិបាលកិច្ចផ្ទៃក្នុងរបស់អង្គការមិនមែនរដ្ឋាភិបាល។ ហើយវាក៏ជាការឆ្លើយតបទៅនឹងគោលការណ៍លេខ ៥ ៦ និង ៧ នៃ គោលការណ៍ទីក្រុងអ៊ីស្តានប៊ុល ស្តីពីប្រសិទ្ធភាពនៃការអភិវឌ្ឍអង្គការសង្គមស៊ីវិល ដែលត្រូវបានអនុម័តនៅទូទាំងពិភពលោកក្នុងឆ្នាំ ២០១០ ។



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

Accountability គណនេយ្យភាព
អភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ GPP
15/01/2009 24/11/2014
Symbol of Trust និមិត្តសញ្ញានៃភាពទុកចិត្ត

នៅខែឧសភាឆ្នាំ ២០១៤ វិញ្ញាបនបត្រចំនួន ៥៩ត្រូវបានផ្តល់ទៅឱ្យអង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ដែលត្រូវបានចូលរួមនៅក្នុង ដំណើរការវិញ្ញាបនបត្រនេះ។

អង្គការដែលទទួលបានវិញ្ញាបនបត្រ ( CNGOs ) ដើរតួនាទី ជាគំរូដ៏សំខាន់មួយ ក្នុងការរួមចំណែក ដល់ការលើកកម្ពស់បទដ្ឋានអប្បបរិមានិងប្រព័ន្ធវិញ្ញាបនបត្រស្ម័គ្រចិត្ត (VCS) ដល់សហាគមន៍អង្គការ មិនមែន រដ្ឋាភិបាល ក៏ដូចជាការចូលរួមក្នុងការចុះវាយតំលៃតាមមូលដ្ឋាន ជាមួយសមាជិកក្រុម NGO GPP ក្នុងការឆ្លើយតបទៅនឹង កំណើនតម្រូវការនៃការដាក់ពាក្យយកវិញ្ញាបនបត្រ។ ពួកគេត្រូវបានគេរំពឹងថានឹង ធ្វើការរួមគ្នាដើម្បីជំរុញប្រព័ន្ធវិញ្ញាបនបត្រស្ម័គ្រចិត្ត VCS និងដើម្បី គោរពតាមគោលការណ៍ ទីក្រុងអ៊ីស្តានប៊ុល ។

ដើម្បីរក្សាបាននូវការអនុវត្តតាមបទដ្ឋានអប្បបរមា និងប្រព័ន្ធវិញ្ញាបនបត្រស្ម័គ្រចិត្ត (VCS) ចំពោះអង្គការមិនមែនរដ្ឋាភិបាល ដែលទទួលបានវិញ្ញាបនបត្រ និងបន្តការលើកកម្ពស់ VCS ។ CCC បានបង្កើតវេទិកានៃការជួបជុំរបស់អង្គការមិនមែនរដ្ឋាភិបាលដែលទទួលបានប្រព័ន្ធវិញ្ញាបនប័ត្រ (CNGO) ចាប់តាំងពីឆ្នាំ ២០១០។ ចាប់តាំងពីពេលនោះមកវេទិកានេះត្រូវបានធ្វើឡើងដោយជោគជ័យ ជារៀងរាល់ ពីរដងក្នុងមួយឆ្នាំ ក្នុងគោលបំណងផ្តល់ជូននូវឱកាសសម្រាប់ CNGOs ដើម្បីពួកគេ ចែករំលែក និងពិភាក្សាលើការ ថែរក្សាបាននូវការអនុលោមទៅតាមស្តង់ដារ ជាមួយគ្នានេះដែរ ពួកគេរួមចំណែកក្នុង ការលើកកម្ពស់ទស្សមានភាព(ភាពអាចមើលឃើញ) និងភាពឲ្យគួរឱ្យជឿទុកចិត្តនៃ VCS ពីភាគី ពាក់ព័ន្ធផ្សេងៗ។ កាលពីឆ្នាំមុនគឺជាវេទិកាលើកទីប្រាំមួយ និងលើកទីប្រាំពីរសម្រាប់ អង្គការ ក្រៅរដ្ឋាភិបាលដែលទទួលបានវិញ្ញាបនប័ត្រ បានធ្វើឡើងដោយជោគជ័យ នៅថ្ងៃទី ០៧ ខែឧសភា ឆ្នាំ ២០១៣ និង ០៥ ខែធ្នូ ឆ្នាំ ២០១៣ និង វេទិកាលើកទីប្រាំបី នឹងត្រូវប្រារព្ធធ្វើឡើង នៅថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០១៤ ដោយមាន គោលបំណង លទ្ធផលរំពឹងទុករយៈពេលមធ្យម និង កម្មវិធីដូចខាងក្រោមនេះ ។

## I.គោលបំណងជាក់លាក់

គោលបំណងសំខាន់ៗនៃវេទិកានេះគឺដើម្បីៈ

1. ចែករំលែក និងធ្វើបច្ចុប្បន្នភាពអំពី ចលនានៃការអភិវឌ្ឍជាសកល របៀបវារៈនៃការអភិវឌ្ឍក្រោយឆ្នាំ២០១៥ និងអភិបាលកិច្ចល្អសម្រាប់ប្រឆាំងអំពើពុករលួយ។
2. ពិភាក្សានិងកំណត់មធ្យោបាយប្រកបដោយប្រសិទ្ធភាពដើម្បីលើកកម្ពស់ទិស្សមានភាព និងកិត្តិនាម និងការធ្វើសំណើរគម្រោងរួមគ្នានៃអង្គការមិនមែនរដ្ឋាភិបាលដែលទទួលបានវិញ្ញាបនបត្រនៃ អភិបាលកិច្ចនិងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ។
3. ពង្រឹងការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាលដែលទទួលបានវិញ្ញាបនបត្រនៃអភិបាលកិច្ចនិងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ។

4. ចែករំលែកជាមួយអង្គការមិនមែនរដ្ឋាភិបាលដែលទទួលបានវិញ្ញាបនបត្រនៃអភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ(GPP) អំពីមធ្យោបាយក្នុងការលើកកម្ពស់និរន្តរភាពហិរញ្ញវត្ថុកាន់តែប្រសើរឡើងនៅក្នុងអង្គការ។

## II. លទ្ធផលដែលបានរំពឹងទុក

1. អង្គការមិនមែនរដ្ឋាភិបាលដែលទទួលបានវិញ្ញាបនបត្រពីកម្មវិធីអភិបាលកិច្ចនិងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈនឹងបានយល់ច្បាស់ និងអភិបាលកិច្ចល្អ ជាមួយនឹងទស្សនទានស្តីពីការប្រឆាំងអំពើពុករលួយ និងការត្រៀមលក្ខណៈដើម្បីសម្របខ្លួនទៅនឹងចលនានៃការអភិវឌ្ឍជាសកលនិងរបៀបវារៈនៃការ អភិវឌ្ឍក្រោយឆ្នាំ២០១៥។
2. កំណត់បាននូវមធ្យោបាយដែលមានសក្តានុពលមួយចំនួនក្នុងការលើកកម្ពស់ទិស្សមានភាព (Visibility) និងកិត្តិនាមនៃអង្គការមិនមែនរដ្ឋាភិបាលដែលទទួលបានវិញ្ញាបនបត្រពីកម្មវិធីអភិបាលកិច្ចនិងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ ។
3. ការបញ្ជៀបផ្នត់គំនិតផ្នែកធុរកិច្ច ដើម្បីឲ្យមានស្ថេរភាពផ្នែកហិរញ្ញវត្ថុកាន់តែប្រសើរឡើងនៅក្នុងអង្គការរបស់ពួកគេ។
4. យន្តការរួមគ្នាត្រូវបានកំណត់ បានពិភាក្សា បានបង្កើតឡើង និងបានអនុវត្តន៍ដើម្បីឲ្យកាន់តែមានភាពប្រសើរឡើងក្នុងការទំនាក់ទំនងនិងកិច្ចសហការ និងធ្វើឲ្យកាន់តែមានស្ថេរភាពនៅក្នុងអង្គការមិនមែនរដ្ឋាភិបាលដែលទទួលបានវិញ្ញាបនបត្រ។

## III. កំរិតអ្នកចូលរួម

ឱកាសក្នុងការចូលរួមវេទិកានេះមានសារៈសំខាន់ណាស់ វាត្រូវបានពង្រីកទៅដល់តំណាងមកពីបណ្តា៤២ អង្គការមិនមែនរដ្ឋាភិបាលដែលទទួលបានវិញ្ញាបនបត្រនៃអភិបាលកិច្ចនិងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ ដែលពួកគាត់អាចជានាយកឬនាយិកាប្រតិបត្តិ ទីប្រឹក្សា ក្រុមប្រឹក្សាភិបាល ឬ ថ្នាក់គ្រប់គ្រង។

## IV. កម្មវិធីលំអិត

| ម៉ោង | ប្រធានបទ | ធនធានវាគ្មិន |
| --- | --- | --- |
| ០៧:៣០-០៨:០០ | ការចុះឈ្មោះ | **លោក ចន្ទ័ ភក្តី** , មន្ត្រីតាមដាន<br>និងត្រួតពិនិត្យនៃអង្គការ CCC/GPP |
| ០៨:០០-០៨:០៥ | ការណែនាំ<br>• ការណែនាំនៃគោលបំណង | **អ្នកស្រី កៅ សុខដែត** , មន្ត្រីប្រពន្ធ័ |

| | | |
|---|---|---|
| | | វិញ្ញាបនបត្រនៃអង្គការ CCC/GPP |
| ០៨:០៥-០៨:២០ | កិច្ចស្វាគមន៍ និង មតិបើកកម្មវិធី | **លោក តាំង ស៊ុនហារ** , នាយកប្រចាំប្រទេសនៃអង្គការជំនួយប្រជាជនណ័រវេ៉ (NPA) និងសមាជិកគណ:កម្មការអនុមតិក្រុម |
| ០៨:២០- ០៨:៣៥ | កិច្ចស្វាគមន៍ និង ការណែនាំអង្គការ ដែលទទួលបានវិញ្ញាបនបត្រថ្មី | **អង្គការជីវិតនៅកម្ពុជា អង្គការមរតក និង មជ្ឈមណ្ឌលអភិវឌ្ឍកុមារនិងស្ត្រីនៅកម្ពុជា** |
| ០៨:៣៥- ០៩:០៥ | **វគ្គទី១**: បច្ចុប្បន្នភាពអំពី ការអភិវឌ្ឍន៍ប្រទេសកម្ពុជានៅឆ្នាំ២០១៥<br><br>សំណួរ និងចម្លើយ | **លោក សឿង សារឿន** , នាយកប្រតិបត្តិនៃអង្គការ CCC |
| ០៩:០៥- ១០:១៥ | **វគ្គទី២**: វេទិកាពិភាក្សាអំពី អភិបាលកិច្ចល្អដើម្បីប្រឆាំងអំពើពុករលួយ<br><br>**<u>បទបង្ហាញទី១</u>**:<br>ការសង្ខេបចំណុចសំខាន់ៗនៃ គោលនយោបាយឬច្បាប់ប្រឆាំងអំពើពុករលួយ<br><br>**<u>បទបង្ហាញទី២</u>**<br>ស្ថានភាពនៃអំពើពុករលួយក្នុងសង្គមកម្ពុជា និងដំណើរ ឆ្ពោះទៅការរកការប្រឆាំងអំពើពុករលួយ<br><br>**<u>បទបង្ហាញទី៣</u>**: : អភិបាលកិច្ចល្អ និងការប្រឆាំងអំពើពុករលួយ | **អ្នកសម្របសម្រួល: កញ្ញា ស៊ិន ពុទ្ធារី** ប្រធានផ្នែកទំនាក់ទំនង និង អភិវឌ្ឍសមាជិកនៃអង្គការ CCC<br><br>**លោក ស្រ៊ិន សុវណ្ណ** ជំនួយការ និង អនុប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ<br><br>**លោក ពេជ្រ ពិសី** នាយកកម្មវិធីនៃអង្គការតម្លាភាព កម្ពុជា<br><br>**លោក ឱក សេរី សុភ័ក្រ្ត**<br>ទីប្រឹក្សាឯករាជ្យ |
| ១០:១៥-១០:៣០ | សម្រាកពិសារអាហារសម្រន់ ការទំនាក់ទំនងសង្គម និងការចងបណ្តាញ | |
| ១០:៣០-១០:៥០ | **វគ្គទី៣**:<br>ការចែករំលែកអំពីការប្របតិបត្តិល្អរបស់អង្គ | **លោក ឈួន វុឌ្ឍី** , ប្រធានអភិវឌ្ឍធនធានមនុស្សនៃអង្គការជីវិតថ្លៃថ្នូរ |

| | | |
|---|---|---|
| | ការទទួលបានវិញ្ញាបនបត្រ | សមាជិក ក្រុមការងារGPP និងអង្គការទទួលបានវិញ្ញាបនបត្រ |
| ១០:៥០-១១:៣០ | ***វគ្គទី៤:*** បច្ចុប្បន្នភាពពីការចុះទស្សនៈកិច្ច និង ការលើកកំពស់ទិស្សមានភាព និងកិត្តិនាមនៃអង្គការដែលទទួលបានវិញ្ញាបនបត្រ<br>• បញ្ហាប្រឈមនានាដែលទទួលបានពីការចុះទស្សនកិច្ច នៃអង្គការនៅក្នុងការដាក់ពាក្យ និងអង្គការដែលទទួលបានវិញ្ញាបនបត្រ<br>• បច្ចុប្បន្នភាពអំពីការចងក្រងសៀវភៅនៃអង្គការដែលទទួលបានវិញ្ញាបនបត្រ***(CNGO directory).***<br>• វេទិកាពិភាក្សា និង ការកំណត់មធ្យោបាយប្រកបដោយប្រសិទ្ធភាពដើម្បីលើកកំពស់កិត្តិនាម និងទស្សនាទាននៃអង្គការដែលទទួលបានវិញ្ញាបនបត្រ | ***លោកស្រី កែវ ម៉ាវ៉ា*** , ឯកទេសធានាគុណភាពនៃ អង្គការ CCC/GPP |
| ១១:៣០-១២:០០ | **<u>បទបង្ហាញ</u>**អំពីក្រម ដែលបានកែសម្រួលថ្មី | **លោក សុខ សុវណ្ណ** , អ្នកជំនាញប្រព័ន្ធវិញ្ញាបនបត្រ នៃអង្គការ CCC/GPP |
| ១២:០០-០១:៣០ | សម្រាកពិសារអាហារថ្ងៃត្រង់ ការទំនាក់ទំនងសង្គម និងការចងបណ្ដាញ | |
| ០១:៣០-០៣:០០ | ***វគ្គទី៥:***<br>បច្ចុប្បន្នភាពការរីកចំរើននៃការគម្រោងសំណើររួមគ្នាដោយប្រធានក្រុមនីមួយៗ<br><br>**<u>បទបង្ហាញទី១</u>**: បច្ចុប្បន្នភាព នៃគម្រោងសំណើររួមគ្នាក្រុមទី១<br><br>**<u>បទបង្ហាញទី២</u>**: បច្ចុប្បន្នភាព នៃគម្រោងសំណើររួមគ្នាក្រុមទី២ | **អ្នកស្រី សរ ម៉ុន្ថា** , ប្រធានកម្មវិធី **GPP** នៃអង្គការ CCC<br><br>**លោក ទេព ប៊ុននី** នាយកប្រតិបត្តិនៃអង្គការសង្គ្រោះសត្វព្រៃ<br><br>**លោក ថន វណ្ណុង ,** នាយកប្រតិបត្តិអង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម<br><br>**លោកស្រី ស៊ឹម ចាន់បូរីណា** , នាយិកា |

| | | |
|---|---|---|
| | **<u>បទបង្ហាញទី៣</u>**: បច្ចុប្បន្នភាព នៃគម្រោងសំណើររួមគ្នាក្រុមទី៣ | ប្រតិបត្តិអង្គការពន្លឺកុមារ |
| ០៣:០០- ០៣:៣០ | **វេទិកាទី៦**:<br>វិធីដើម្បីអោយមានស្ថេរភាពផ្នែកហិរញ្ញវត្ថុនៅក្នុងអង្គការ | **លោក ឱ ចាន់នី** , នាយកប្រតិបត្តិអង្គការ ក្រុមអភិវឌ្ឍន៏ជនបទកម្ពុជា |
| ០៣:៣០-០៣:៤៥ | សម្រាកពិសារអាហារសម្រន់ ការទំនាក់ទំនងសង្គម និងការចងបណ្តាញ | |
| ០៣:៤៥- ០៤:៣៥ | **វេទិកាទី៧**:<br>មធ្យោបាយដែលអាចធ្វើទៅបានដើម្បីបំលែងអង្គការក្លាយទៅជាស្ថាប័នធុរកិច្ចគំរូ | **លោកឱម សេងបូរា**<br>ប្រធានមជ្ឈមណ្ឌលអគនាយក និងសហាគ្រិនអាស៊ី |
| ០៤:៣៥- ០៤:៤៥ | **វេទិការទី៨**: វេទិការពិភាក្សា<br>• ការវាយតម្លៃកម្មវិធី | **លោក ហាក់ គន្ធី**, មន្ត្រីប្រពន្ធ័វិញ្ញាបនបត្រនៃអង្គការ CCC/GPP |
| ០៤:៤៥-០៥:០០ | **មតិបិទកម្មវិធី** | **លោក ខៀវ វិជ្ជានន្ទ** , អគ្គលេខាធិការរងនៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា និងជាសមាជិកប្រតិបត្តិ នៃបណ្តាញធានាគុណភាពអាស៊ាន និងសមាជិកក្រុមការងារ GPP |

<u>*សំគាល់*</u>:

☞ CCC រក្សាកម្មវិធីត្រឹមត្រូវនៅពេលក្រោយទៀតដោយផ្អែកទៅលើលទ្ធភាពធនធាន និងពេលវេលារបស់វាគ្មិន

☞ CCC នឹងត្រូវបានគាំទ្រអ្នកចូលរួមតែម្នាក់ប៉ុណ្ណោះដែលអញ្ជើញមកពីតំណាងអង្គការដែលទទួលបានវិញ្ញាបនបត្រដោយផ្អែកទៅលើគោលនយោបាយធ្វើដំណើររបស់អង្គការ CCC និងភ្ជាប់ឯកសារមកជាមួយ។ <u>*ស៊ី ស៊ី ស៊ី នឹងមិនផ្តល់ជូនឡើយ ប្រសិនបើមិនមានវិក័យបត្រឬបង្កាន់ដៃបង់ប្រាក់ភ្ជាប់មកជាមួយ។*</u>